JobAccess
Driving disability employment

# ប័ណ្ណព័ត៌មាន
# សេវាការងារសម្រាប់ជនពិការ

សេវាការងារសម្រាប់ជនពិការ (Disability Employment Services) (DES)
គឺជាអ្នកមានចុះកិច្ចសន្យាផ្តល់សេវាការងារ និងការគាំទ្រផ្សេងៗរបស់រដ្ឋាភិបាល ។
អ្នកផ្តល់សេវាទាំងនេះជួយបណ្តាជនដែលមានសិទ្ធិទទួល ដែលមានពិការភាព របួស
ឬលក្ខណៈសុខភាពនានាក្នុងការស្វែងរក និងរក្សាការងារ។

អ្នកផ្តល់សេវា DES គឺជាអ្នកជំនាញក្នុងការភ្ជាប់ជនពិការជាមួយនិងអ្នកដែលអាចជានិយោជករបស់ពួកគេ
។ អ្នកផ្តល់សេវាទាំងនេះធ្វើការផ្ទាល់ជាមួយនឹងជនពិការដើម្បីជួយពួកគេអោយទទួលបានការងារ
តាមមធ្យោបាយរាវរកឲ្យដឹងពីជំនាញ សញ្ញាប័ត្រ បទពិសោធន៍ការងារ
និងគោលដៅអាជីពរបស់ជនពិការទាំងនោះ ។ គេដឹងថាមានការងារនៅទីណា
ហើយត្រូវធ្វើដូចម្តេចដើម្បីជួយជនពិការស្វែងរក និងរក្សាការងារ។

នៅពេលដែលជនពិការម្នាក់បានទទួលការងារមួយ អ្នកផ្តល់សេវា DES នោះនឹងផ្តល់ការគាំទ្រការងារ
រយៈពេលយ៉ាងហោចណាស់ 26 សប្តាហ៍ ប៉ុន្តែក៏អាចបន្តជួយទាំងនិយោជិកនិងនិយោជក
សម្រាប់រយៈពេលយូរដែលពួកគេត្រូវការ ។

សំរាប់និយោជក DES អាចផ្តល់សេវាដោយឥតគិតថ្លៃជាច្រើន រួមទាំងការជួយផ្តល់ការងារ
និងរក្សាបុគ្គលិកជាជនពិការវ័យក្មេង។

បើចង់ជ្រាបច្បាស់ថាតើអ្នកអាចទទួលបានការជួយពី DES ឬទេ
សូមទាក់ទងមកក្រសួងសេវាធនធានមនុស្ស (Centrelink) ។ អ្នកអាចចុះឈ្មោះជាមួយនឹងអ្នកផ្តល់សេវា DES

Australian Government

JobAccess is the national hub for workplace and employment information for people with disability, employers and service providers.

**1800 464 800** **www.jobaccess.gov.au**

នៅក្នុងតំបន់អ្នកផ្ទាល់ផងដែរ ។ បញ្ជីឈ្មោះ អ្នកផ្តល់សេវា DES ក្នុងតំបន់អ្នកអាចរកបានតាមរយៈគេហទំព័រ jobactive នៅ www.jobsearch.gov.au ។

សំរាប់ព័ត៌មានបន្ថែមស្តីអំពីការងារសម្រាប់ជនពិការ សូមមើលគេហទំព័រ www.jobaccess.gov.au ឬក៏ទាក់ទងមកអ្នកផ្តល់យោបល់របស់ JobAccess តាមលេខ 1800 464 800-
ការទាក់ទងតាមទូរសព្ទ័ដៃត្រូវគេគិតថ្លៃ។